ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងយុត្តិធម៌

លេខ :០១៣៧យ.សណន/៦៣

# សេចក្តីណែនាំ
## ស្តីពី
## នីតិវិធីដែលត្រូវអនុវត្តចំពោះជនរងគ្រោះជាអនីតិជន នៅក្នុងសំណុំរឿងព្រហ្មទណ្ឌ

កន្លងមក ក្រសួងយុត្តិធម៌បានកត់សម្គាល់ឃើញថា ចៅក្រម និងព្រះរាជអាជ្ញា នៅតាមសាលាជម្រះក្តី និងអង្គការអយ្យការអមសាលាជម្រះក្តី បានខិតខំបំពេញតួនាទី និងភារកិច្ចរបស់ខ្លួនដែលច្បាប់ប្រគល់ឱ្យក្នុងការដោះស្រាយរឿងក្តីព្រហ្មទណ្ឌ ដោយអនុវត្តទៅតាមបទប្បញ្ញត្តិនៃក្រមនីតិវិធីព្រហ្មទណ្ឌ និងបទប្បញ្ញត្តិពាក់ព័ន្ធជាធរមាន ជាពិសេស ដើម្បីស្រាវជ្រាវស្វែងរកការពិត និងផ្តល់យុត្តិធម៌តាមផ្លូវច្បាប់ជូនភាគីពាក់ព័ន្ធ ក៏ដូចជាដើម្បីធានាប្រសិទ្ធភាពនៃការអនុវត្តច្បាប់។ ប៉ុន្តែទោះជាយ៉ាងនេះក្តី ការអនុវត្តនូវកិច្ចនីតិវិធីមួយចំនួនរបស់ស្ថាប័នអយ្យការ និងស្ថាប័នតុលាការ នៅមិនទាន់ឆ្លើយតបបានល្អប្រសើរទៅនឹងសំណូមពរនៃស្ថានភាពពិសេសដោយឡែកជាក់ស្តែងមួយចំនួននៅក្នុងរឿងក្តីព្រហ្មទណ្ឌ ជាពិសេស ចំពោះភាគីជនរងគ្រោះជាអនីតិជន ដែលប្រការនេះ មិនត្រឹមតែអាចធ្វើឱ្យប៉ះពាល់ដល់ប្រសិទ្ធភាពនៃដំណើរការស្វែងរកការពិតនៅក្នុងរឿងក្តីប៉ុណ្ណោះទេ ប៉ុន្តែ ក៏អាចធ្វើឱ្យប៉ះពាល់ដល់ឧត្តមប្រយោជន៍របស់ជនរងគ្រោះជាអនីតិជន ដែលត្រូវបានការពារដោយច្បាប់ជាតិផង និងច្បាប់អន្តរជាតិផង។

ក្នុងន័យនេះ ដើម្បីធានាដំណើរការល្អប្រសើរនៅក្នុងរឿងក្តីព្រហ្មទណ្ឌ ទាំងលើប្រសិទ្ធភាពនៃការស្រាវជ្រាវស្វែងរកការពិតស្របតាមបទប្បញ្ញត្តិផ្នែកនីតិវិធីព្រហ្មទណ្ឌផង ទាំងលើការការពារឧត្តមប្រយោជន៍របស់ជនរងគ្រោះជាអនីតិជននៅក្នុងសំណុំរឿងផង, ក្រសួងយុត្តិធម៌សូមធ្វើការណែនាំអំពីនីតិវិធីចាំបាច់មួយចំនួន ដែលត្រូវយកចិត្តទុកដាក់អនុវត្តឱ្យបានល្អសម្រាប់ជនរងគ្រោះជាអនីតិជននៅក្នុងសំណុំរឿងក្តីព្រហ្មទណ្ឌ ដូចខាងក្រោម៖

### ១-ក្នុងដំណាក់កាលស៊ើបអង្កេត

- ព្រះរាជអាជ្ញា ត្រូវយកចិត្តទុកដាក់ក្នុងការអនុវត្តនីតិវិធីតាមច្បាប់ ដោយត្រូវបង្កលក្ខណៈទាំងលើទិដ្ឋភាពផ្នែកសត្យានុម័ត ទាំងលើទិដ្ឋភាពផ្នែកចិត្តសាស្ត្រ ដើម្បីអនុញ្ញាតឱ្យជនរងគ្រោះជាអនីតិជនអាចធ្វើការប្តឹង និងផ្តល់ចម្លើយឱ្យបានច្បាស់លាស់ទាក់ទងនឹងអង្គហេតុនៃបទល្មើសដែលបានកើតឡើង សំដៅរកឱ្យឃើញការពិតនៅក្នុងរឿងក្តី ដោយចៀសវាងឱ្យបាននូវការផ្តល់ចម្លើយស្ថិតក្នុងស្ថានភាពតក់ស្លុត ឬភ័យខ្លាចដោយប្រការណាមួយ។



មហាវិថីសម្តេចសុធារស.ខ័ណ្ឌដូនពេញ.រាជធានីភ្នំពេញ ទូរស័ព្ទ : 023 216 322, 023 217 841, 023 212 693

- ក្នុងករណីចាំបាច់ ចំពោះជនរងគ្រោះជាអនីតិជនដែលស្ថិតក្នុងស្ថានភាពមិនអាចធ្វើដំណើរបាន ជាពិសេស សម្រាប់អនីតិជនដែលមានអាយុក្រោម ១០ (ដប់)ឆ្នាំយ៉ាងតិច, ព្រះរាជអាជ្ញា អាចចុះទៅកាន់លំនៅឋាន ឬទីកន្លែងដែលជនរងគ្រោះជាអនីតិជននោះស្ថិតនៅដោយផ្ទាល់ ដើម្បីស្តាប់ចម្លើយ ក៏ដូចជាអនុវត្តកិច្ចនីតិវិធីចាំបាច់ផ្សេងទៀត។

- ក្នុងការស្តាប់ចម្លើយរបស់ជនរងគ្រោះជាអនីតិជន, ព្រះរាជអាជ្ញា ត្រូវយកចិត្តទុកដាក់ធ្វើការណែនាំឱ្យមានការធ្វើកំណត់ហេតុមួយ ដែលមានលក្ខណៈច្បាស់លាស់ និងគ្រប់ជ្រុងជ្រោយ ទាំងលើសំណួរ ទាំងលើចម្លើយ ក៏ដូចជាការកត់សម្គាល់នានានៅពេលស្តាប់ចម្លើយ ដើម្បីអាចយកធ្វើជាមូលដ្ឋានសម្រាប់ការប្រើប្រាស់នៅគ្រប់ដំណាក់កាលនៃនីតិវិធីព្រហ្មទណ្ឌ នាពេលក្រោយមកទៀត។

- ដើម្បីធានាដល់ការអនុវត្តគោលការណ៍ខាងលើនៅក្នុងដំណាក់កាលស៊ើបអង្កេត, ព្រះរាជអាជ្ញា ត្រូវធ្វើការណែនាំដល់នគរបាលយុត្តិធម៌ទាំងអស់ដែលស្ថិតក្រោមសមត្ថកិច្ចដែនដីរបស់ខ្លួន ឱ្យអនុវត្តតាមការណែនាំខាងលើនេះ ទាំងការស្តាប់ចម្លើយ ទាំងការធ្វើកំណត់ហេតុនៃការស្តាប់ចម្លើយរបស់អនីតិជនដែលជាជនរងគ្រោះនៃបទល្មើស។

## ២-ក្នុងដំណាក់កាលស៊ើបសួរ

ចៅក្រមស៊ើបសួរ ត្រូវបំពេញកិច្ចស៊ើបសួរទាំងអស់ដែលខ្លួនយល់ថាមានប្រយោជន៍សម្រាប់បង្ហាញឱ្យឃើញការពិតដោយអនុលោមតាមច្បាប់ ស្របតាមមាត្រា១២៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។ ក្នុងស្មារតីនេះ, ចៅក្រមស៊ើបសួរ ត្រូវយកចិត្តទុកដាក់ក្នុងការអនុវត្តនីតិវិធីតាមច្បាប់ ដោយត្រូវបង្កលក្ខណៈសមស្រប ទាំងលើទិដ្ឋភាពផ្នែកសត្យានុម័ត ទាំងលើទិដ្ឋភាពផ្នែកចិត្តសាស្ត្រ ដើម្បីអនុញ្ញាតឱ្យជនរងគ្រោះជាអនីតិជនធ្វើការបំភ្លឺ និងផ្តល់ចម្លើយឱ្យបានច្បាស់លាស់ទាក់ទងនឹងអង្គហេតុនៃបទល្មើសដែលបានកើតឡើង សំដៅរកឱ្យឃើញការពិតនៅក្នុងរឿងក្តី ដោយចៀសវាងឱ្យបាននូវការផ្តល់ចម្លើយស្ថិតក្នុងស្ថានភាពតក់ស្លុត ឬភ័យខ្លាចដោយប្រការណាមួយ។ ជាមួយគ្នានេះ, ចំពោះជនរងគ្រោះជាអនីតិជនដែលស្ថិតក្នុងស្ថានភាពមិនអាចធ្វើដំណើរបាន ជាពិសេស សម្រាប់អនីតិជនដែលមានអាយុក្រោម ១០ (ដប់)ឆ្នាំយ៉ាងតិច ចៅក្រមស៊ើបសួរ អាចចុះទៅកាន់លំនៅឋាន ឬទីកន្លែងដែលជនរងគ្រោះជាអនីតិជននោះស្ថិតនៅដោយផ្ទាល់ ដើម្បីស្តាប់ចម្លើយ ឬបំពេញកិច្ចនីតិវិធីចាំបាច់ផ្សេងទៀតដោយអនុលោមតាមច្បាប់។

## ៣-ក្នុងដំណាក់កាលជំនុំជម្រះ

- ជនរងគ្រោះជាអនីតិជន អាចត្រូវបានអមដោយមេធាវី ឬអាចត្រូវបានតំណាងដោយមេធាវី ឬអ្នកតំណាងស្របច្បាប់របស់ខ្លួន ក្នុងពេលសវនាការ ស្របតាមមាត្រា៣១៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។ ក្នុងស្មារតីនេះ, បន្ថែមលើកិច្ចនីតិវិធីផ្សេងទៀតដែលបានអនុវត្តដោយតុលាការតាមក្រមនីតិវិធីព្រហ្មទណ្ឌ ចៅក្រមជំនុំជម្រះ ត្រូវជូនដំណឹងដល់មេធាវី ឬតំណាងស្របច្បាប់អំពីសិទ្ធិនេះ ដើម្បីជនរងគ្រោះចូលរួមក្នុងសវនាការដោយផ្ទាល់អមដោយវត្តមានរបស់មេធាវី ឬអាចឱ្យមេធាវីឬតំណាងស្របច្បាប់របស់ខ្លួនផ្សេងទៀតចូលរួមជំនួសក្នុងសវនាការ ដោយអនុលោមតាមមាត្រា៣១៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

- ក្នុងករណីមានភាពចាំបាច់បំផុតក្នុងការផ្ទៀងផ្ទាត់អត្តសញ្ញាណរបស់ជនល្មើស ក៏ដូចជាការបំភ្លឺលើចំណុចលម្អិតមួយចំនួន ដែលជាមូលដ្ឋានចាំបាច់ក្នុងការសម្តែងឱ្យឃើញការពិតក្នុងរឿងក្តី, ចៅក្រមជំនុំជម្រះ ត្រូវរៀបចំដំណើរការនីតិវិធី ដោយប្រើប្រាស់វិធីសាស្ត្រប្រយោល តាមរយៈការប្រើប្រាស់របាំង ឬរូបថត ឬប្រើប្រាស់វិធីសមស្របផ្សេងទៀត ដោយធ្វើយ៉ាងណាចៀសវាងឱ្យបានជាអតិបរមានូវការជួបតទល់ដោយផ្ទាល់រវាងជនល្មើស និងជនរងគ្រោះជាអនីតិជន ដែលអាចបង្កឱ្យជនរងគ្រោះមានការភ័យខ្លាច ឬតក់ស្លុត ដែលអាចប៉ះពាល់ដល់ការស្វែងរកការពិតផង និងប៉ះពាល់ដល់ជនរងគ្រោះខាងផ្នែកសតិអារម្មណ៍ផង។

- ដើម្បីធានាដល់ការការពារកិត្តិយស ឯកជនភាព និងចៀសវាងការបង្កនូវភាពភ័យខ្លាចដល់ជនរងគ្រោះជាអនីតិជន, ចៅក្រមជំនុំជម្រះ ត្រូវយកចិត្តទុកដាក់ពិចារណាអំពីការរៀបចំដំណើរការសវនាការជាអសាធារណៈ ស្របតាមមាត្រា៣១៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

ទទួលបានការណែនាំនេះ សូម **ឯកឧត្តម លោកជំទាវ** ដែលជាប្រធានសាលាដំបូង **និងជាព្រះរាជអាជ្ញាអមសាលាដំបូងរាជធានី ខេត្ត** ត្រូវចាត់ចែងអនុវត្តសេចក្តីណែនាំនេះ ឱ្យមានប្រសិទ្ធភាពស្របតាមគោលបំណង និងស្មារតីនៃច្បាប់ សំដៅបង្កើនប្រសិទ្ធភាពនៃយុត្តិធម៌ព្រហ្មទណ្ឌ និងពង្រឹងនីតិរដ្ឋនៅកម្ពុជា។

ថ្ងៃ ពុធ ១៣កើត ខែ បុស្ស ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦

រាជធានីភ្នំពេញ ថ្ងៃទី ៤ ខែ មករា ឆ្នាំ២០២៣

**រដ្ឋមន្ត្រីក្រសួងយុត្តិធម៌**

**កើត រិទ្ធ**

**ចម្លងជូន៖**

-ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម

-តុលាការកំពូល និងមហាអយ្យការអមតុលាការកំពូល

-សាលាឧទ្ធរណ៍ និងមហាអយ្យការអមសាលាឧទ្ធរណ៍ទាំងអស់

-ឯកសារ កាលប្បវត្តិ